**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ៥២០ ជនស/ អរបម/នី.ភ

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២២

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** ការទប់ស្កាត់ការសាងសង់ឬរុះរើសំណង់ដែលគ្មានលិខិតអនុញ្ញាត

**យោង៖**
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- អនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសរួមលេខ១២២៩ ប្រក.មផ.ជនស ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាបថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនអនុញ្ញាតឱ្យមានការដ្ឋានសំណង់ចាប់ផ្តើមដំណើរការសាងសង់ឬរុះរើ ដោយគ្មានប្លង់ស្ថាបត្យកម្មនិងប្លង់គ្រឿងផ្គុំសំណង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចឡើយ។ សកម្មភាពទាំងនេះជាអំពើខុសច្បាប់ ដែលអាចបង្កឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិស្តីពីផ្លាតម្លាត គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ សណ្តាប់ធ្នាប់សាធារណៈ សោភណភាព ការរស់នៅប្រកបដោយចីរភាព និងអាចបង្កឱ្យមានវិវាទ។

ក្នុងន័យនេះ ក្រសួងស្នើ **ឯកឧត្តម លោកជំទាវអភិបាល** ជំរុញការតាមដានត្រួតពិនិត្យចាត់វិធានការទប់ស្កាត់ការសាងសង់ឬរុះរើសំណង់ដែលគ្មានលិខិតអនុញ្ញាត និងចាត់ចែងដាក់ទណ្ឌកម្មចំពោះជនដែលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីសំណង់ មានជាអាទិ៍ ការតម្រូវឱ្យម្ចាស់សំណង់កែសម្រួលឬរុះរើសំណង់ ការហាមឃាត់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាដូចជាការមិនអនុញ្ញាតឱ្យធ្វើការបញ្ជាក់ ការដាក់ហ៊ីប៉ូតែក ការផ្ទេរ ឬលក់-ទិញ ពាក់ព័ន្ធនឹងសំណង់ដែលគ្មានលិខិតអនុញ្ញាត និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីស្នើសុំរឹបអូសសម្ភារៈ បរិក្ខារ និងឧបករណ៍ផ្សេងៗទៀត ការផ្តន្ទាទោសពិន័យជាប្រាក់ ការផ្តន្ទាទោសដាក់ពន្ធនាគារ ការរំលាយ

ក្រុមហ៊ុន ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ការហាមឃាត់ចំពោះការធ្វើសកម្មភាព ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស និងការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសជាសាធារណៈ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាប អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងរាយការណ៍មកក្រសួងវិញ។

សូម **ឯកឧត្តម លោកជំទាវអភិបាល** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងពាណិជ្ជកម្ម

-គ្រប់អគ្គនាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-គ្រប់សាលារាជធានី ខេត្ត

-គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត

-ឯកសារ កាលប្បវត្តិ